ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ.....សហវ.....

រាជធានីភ្នំពេញ,ថ្ងៃទី.....ខែ.....ឆ្នាំ ២០១៣

ប្រកាស
ស្តីពីការបង្វែរឥណទានដូនរដ្ឋបាលក្រុង ស្រុកនៃខេត្តកែប សម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៣

ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១១/០១១ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១១ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីរបបហិរញ្ញវត្ថុនិងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១២/០១០ ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១២ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៣
- បានឃើញអនុក្រឹត្យលេខ ០៨ អនក្រ.បក ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០០០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១១២/០០៤ ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០១២ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីលទ្ធកម្មសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ០៦ អនក្រ.បក ចុះថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០០៣ ស្តីពីការបង្កើតនាយកដ្ឋានហិរញ្ញវត្ថុមូលដ្ឋាននៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ.បក ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០០៨ និងអនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី ២៩ ខែមីនា ឆ្នាំ២០០៨ ស្តីពីការបំពេញបន្ថែម និងកែសម្រួលនាយកដ្ឋានមួយចំនួននៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញប្រកាសលេខ ៦២៩ សហវ.ប្រក.ហម ចុះថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០១១ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃនាយកដ្ឋានហិរញ្ញវត្ថុមូលដ្ឋាន
- បានឃើញអនុក្រឹត្យលេខ ១៣៨ អនក្រ.បក ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតម្លើងទីចាត់ការគយ និងរដ្ឋាករនាយកដ្ឋានពន្ធដារ និងរតនាគារជាតិ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អោយទៅជាអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា អគ្គនាយកដ្ឋានពន្ធដារ និងអគ្គនាយកដ្ឋានរតនាគារជាតិ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- បានឃើញអនុក្រឹត្យលេខ ២៧៥ អនក្រ.បក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១២ ស្តីពីការបែងចែកឥណទានចំណូលថវិកាថ្នាក់ជាតិតាមជំពូកនៃច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៣
- បានឃើញអនុក្រឹត្យលេខ ២៧៦ អនក្រ.បក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១២ស្តីពីការបែងចែកឥណទានចំណាយថវិកាថ្នាក់ជាតិតាមជំពូកនៃច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៣
- បានឃើញអនុក្រឹត្យលេខ ៣៦ អនក្រ.បក ចុះថ្ងៃទី០៧ ខែមីនា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃមូលនិធិក្រុង ស្រុក
- បានឃើញអនុក្រឹត្យលេខ ១៧២ អនក្រ.បក ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ២០១៣ ស្តីពីប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុរបស់ក្រុង ស្រុក
- បានឃើញប្រកាសលេខ.២០៣ ប្រក សហវ.ច ចុះថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៩៩ ស្តីពីបទបញ្ជាថវិកាខេត្ត ក្រុង
- បានឃើញសារាចរណែនាំលេខ ០០៨ សហវ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១២ ស្តីពីការអនុវត្តថវិការដ្ឋបាលថ្នាក់ក្រោមជាតិឆ្នាំ២០១៣
- បានឃើញប្រកាសលេខ ២៨៥ សហវ.ហម ចុះថ្ងៃទី១៨ ខែមិថុនា ឆ្នាំ២០១២ ស្តីពីការដាក់ឲ្យអនុវត្តចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញប្រកាសលេខ ១០៨៧ សហវ.ហម ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ ២០១២ ស្តីពីការប្រគល់កាតព្វកិច្ចប្រមូលចំណូលនិងការបែងចែកឥណទានចំណាយថវិការបស់រដ្ឋបាលក្រុង ស្រុក សម្រាប់ការគ្រប់គ្រងឆ្នាំ២០១៣
- បានឃើញសេចក្តីជូនដំណឹងលេខ ០០៣ សហវ.ហម ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ២០១៣ ស្តីពីការអនុវត្តចំណាយថវិកាក្រុង ស្រុកសម្រាប់ឆ្នាំ២០១៣
- យោងសំណើលេខ ០៧១ សណ.សដច/១៣ ចុះថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០១៣ របស់សាលាស្រុកដំណាក់ចង្អើរ
- យោងសំណើលេខ ០២៧ សណ-ក្រក/១៣ ចុះថ្ងៃទី០៩ ខែកក្កដា ឆ្នាំ២០១៣ របស់សាលាក្រុងកែប
- តាមការចាំបាច់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

សម្រេច

ប្រការ១: ត្រូវបានប្រតិបត្តិនៅក្នុងរង្វង់ថវិការបស់រដ្ឋបាលក្រុង ស្រុកចំនួន២/២នៃខេត្តកែប សម្រាប់ការគ្រប់គ្រងឆ្នាំ២០១៣ នូវការបង្វែរឥណទានដូចមានក្នុងតារាងខាងក្រោមនេះ ៖

ឯកតា: ពាន់រៀល

ជំពូក	គណៈ	អនុគណៈ	ចំណាត់ថ្នាក់ចំណាយ	ច្បាប់ហិរញ្ញវត្ថុ ឆ្នាំ ២០១៣	ឥណទានកែប្រែ		ឥណទានថ្មី
					កើន	ថយ	
១-ស្រុកដំណាក់ចង្អើរ							
62	622		ទំនាក់ទំនងសាធារណៈ និងការផ្សព្វផ្សាយ				
		6221	សោហ៊ុយទទួលភ្ញៀវជាតិ	1,000	2,500	0	3,500
	624		ចំណាយទុទាត់សោហ៊ុយក្នុងប្រទេស				
		6241	សោហ៊ុយដឹកជញ្ជូន	1,000	700	0	1,700
		6242	សោហ៊ុយបេសកកម្ម	3,000	2,700	0	5,200
		6243	សោហ៊ុយស្នាក់នៅ	5,000	2,400	0	7,400
64	641	6411	ប្រាក់បំណាច់អភិបាលក្រុង ស្រុក ខណ្ឌ	7,800	100	0	7,900
		6412	ប្រាក់បំណាច់អភិបាលរងក្រុង ស្រុក ខណ្ឌ	2,500	100	0	2,600
	642	6421	របៀវត្សមូលដ្ឋាន	102,800	4,500	0	107,300
09			ចំណាយមិនបានគ្រោងទុក	13,000	0	13,000	0
សរុប				**136,100**	**13,000**	**13,000**	**136,100**
២-ក្រុងកែប							
62	622		ទំនាក់ទំនងសាធារណៈ និងការផ្សព្វផ្សាយ				
62	622	6221	សោហ៊ុយទទួលភ្ញៀវជាតិ	1,000	3,000	0	4,000

-	624		ចំណាយទូទាត់សោហ៊ុយក្នុងប្រទេស				
		6241	សោហ៊ុយដឹកជញ្ជូន	1,000	300	0	1,300
		6242	សោហ៊ុយបេសកកម្ម	2,000	600	0	2,600
		6243	សោហ៊ុយស្នាក់នៅ	4,000	1,000	0	5,000
64	641	6412	ប្រាក់បំណាច់អភិបាលរងក្រុង ស្រុក ខណ្ឌ	2,840	200	0	3,040
	642	6421	បៀវត្សមូលដ្ឋាន	104,810	5,100	0	109,910
	644	6443	បៀវត្សមូលដ្ឋានបុគ្គលិកអណ្តែត	3,750	0	3,750	0
	645	6451	ប្រាក់បំណាច់ជាលក្ខណៈគ្រួសារ				
			កូនរៀនវិទ្យាល័យ អនុវិទ្យាល័យ	200	0	200	0
		6454	ឧបត្ថម្ភនិវត្តជន	0	3,750	0	3,750
09			ចំណាយមិនបានគ្រោងទុក	10,000	0	10,000	0
សរុប				**125,850**	**13,950**	**13,950**	**125,850**
សរុបរួម				**261,950**	**26,950**	**26,950**	**261,950**

ប្រការ២: អភិបាលនៃគណៈអភិបាលស្រុកដំណាក់ចង្អើរ ក្រុងកែបនៃខេត្តកែប ជាអ្នកទទួលបន្ទុកអនុវត្តប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។ អ៊ុក ណាវ៉ង់ ស្តី

ឧបនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

គាត ឈន់

ចម្លងជូន:
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
-ដើម្បីជូនជ្រាប-
- អគ្គនាយកដ្ឋានរតនាគារជាតិ
- មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុខេត្តកែប
- រតនាគារខេត្តកំពត
-ដើម្បីអនុវត្ត-
- ឯកសារ